122/12

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៩៩

ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣

សាលដីកា

លេខ: ៣០៥

ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៤៤ "ក្រIVត" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៩៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ របស់តុលាការកំពូល។

ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ៥ ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ២១៧ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

១-ជនជាប់ចោទឈ្មោះ [redacted] "ជាម្ចាស់បណ្ដឹងសាទុក្ខ" ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្នផ្ទះលេខ២១៨ ផ្លូវ៨៦ ភូមិ២២ ក្រុម២៧៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោ [redacted] ាយឈ្មោ [redacted] ឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន ។ ឃុំខ្លួនថ្ងៃទី០៤-០៩-២០១២។



Scanned by CamScanner

២-ជនជាប់ចោទឈ្មោះ [redacted] "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅភូមិឬស្សីក្រោក ឃុំឬស្សីក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ និងទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ២១៨ ផ្លូវលេខ៨៦ ភូមិ២២ ក្រុម២៧៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន។ ក្រៅឃុំ

-មានមេធាវីលោក [redacted]

៣-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ។ (គេចខ្លួន)

៤-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ។ (គេចខ្លួន)

១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៨ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅផ្ទះជួល ផ្លូវ៨៦ ភូមិ១២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៥ឆ្នាំ ទីលំនៅបច្ចុប្បន្នផ្ទះជួល ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-មានមេធាវីលោក [redacted]

-កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង១៩និង១០នាទីនៅមុខផ្ទះសំណាក់បុប្ផា មានករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស មួយបានកើតឡើងដែលមាន ឈ្មោះ [redacted] និងប្តីបាននាំបងប្អូនឈ្មោះ [redacted] បានដើរសំដៅជនរងគ្រោះឈ្មោះ [redacted] ឈ្មោះ [redacted] ដែលអង្គុយចាំម៉ូយនៅ នឹងកន្លែងកើតហេតុខាងលើ ពេលនោះឈ្មោះ [redacted] បានចាប់គៀកឈ្មោះ [redacted] ហើយយកទុយលីវីសចាក់នៅលើក្បាលបណ្តាលឱ្យរងរបួសជាច្រើនកន្លែង និងចាក់ចំខ្នង ចំពោះដៃផុតចំនួន០១កន្លែង រីឯឈ្មោះ [redacted] បានយកពូថៅកាប់ទៅលើឈ្មោះ [redacted] ចំក្បាលរបួស០២កន្លែង បណ្តាលឱ្យហូរឈាម ភ្លាមៗនោះឪពុករបស់ឈ្មោះ [redacted] និងអ្នកជិតខាងបានចូលឃាត់ចាប់ជនល្មើសម្នាក់ឈ្មោះ [redacted] ជាបងស្រីបង្កើតរបស់ឈ្មោះ [redacted] និងប្តីបានមកជួយរំដោះប្អូនឱ្យរួចគេចខ្លួនបាត់អស់ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា:

-របាយការណ៍សំយោគរបស់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ ចំលើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ចំលើយរបស់សាក្សីឈ្មោះ [redacted] ឈ្មោះ [redacted] ព្រមទាំងឯកសារមួយចំនួនដែលទាក់ទងនឹងសំណុំរឿង អាចសន្និដ្ឋានបានថា: ជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនាមានស្ថានទំងន់ទោស កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង១៩និង១០នាទី នៅចំណុចមុខផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះ



Scanned by CamScanner

លេខ៥ ផ្លូវលេខ៨៦ ភូមិទី២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ លើជនរងគ្រោះឈ្មោះ [redacted] បណ្ដាលអោយរបួសជាទម្ងន់ប្រាកដមែន។

-ចំពោះចំលើយដែលឈ្មោះ [redacted] និងឈ្មោះ [redacted] បានឆ្លើយដោះសារនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ពួកខ្លួនមិនបានចូលទៅជួយប្រតាយប្រតប់រំដោះអោយឈ្មោះ [redacted] រត់គេចខ្លួននោះទេ ប៉ុន្តែតាមការបញ្ជាក់របស់ជនរងគ្រោះឈ្មោះ [redacted] បានបញ្ជាក់យ៉ាងច្បាស់ថា នៅពេលកើតហេតុមានឈ្មោះ [redacted] ពិតជាបានមកប្រតាយប្រតប់ដណ្ដើមឈ្មោះ [redacted] និង [redacted] អោយរត់គេចខ្លួនប្រាកដមែន។

-ទង្វើរបស់ឈ្មោះ [redacted] ឈ្មោះ [redacted] បានធ្វើអោយប៉ះដល់សណ្ដាប់ធ្នាប់របៀបរៀបរយក្នុងសង្គម និងរូបរាងកាយរបស់រូបវ័ន្តបុគ្គលដែលច្បាប់បានការពារ និងហាមឃាត់។

-មានភស្តុតាងគ្រប់គ្រាន់សំរាប់ដាក់បន្ទុកលើ ១/.ឈ្មោះ [redacted] ភេទស្រី អាយុ២៨ឆ្នាំ, ២/[redacted] ស អាយុ៥៦ឆ្នាំ, ៣/.ឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ និង៤/.ឈ្មោះ [redacted] ទប្រុស អាយុ២៧ឆ្នាំ ពីបទ: ហិង្សាដោយចេតនា (ស្ថានទម្ងន់ទោស) ប្រព្រឹត្តនៅចំណុចមុខផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ៥ ផ្លូវលេខ៨៦ ភូមិទី២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១០៧ "ឃ" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច:

១-ផ្ដន្ទាទោសលើជនជាប់ចោទដូចខាងក្រោម៖

-ឈ្មោះ [redacted] ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ (បីឆ្នាំ) (កំពុងជាប់ឃុំ)។

-ឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ (បីឆ្នាំ) (កំពុងរត់គេចខ្លួន)។

-ឈ្មោះ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ (បីឆ្នាំ) (កំពុងរត់គេចខ្លួន)។

-ឈ្មោះ [redacted] ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ (បីឆ្នាំ) តែអោយទទួលទោសគុកព្យួរទាំងអស់។

ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ៥ ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១២។



Scanned by CamScanner

បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១០៦, ១០៧, ១០៨ និងមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់អោយជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ, [redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ រួមគ្នាសងសំណងអន្តរាយផ្សេងៗ និងជម្ងឺចិត្តដល់ដើមបណ្តឹង និងជាជនរងគ្រោះចំនួនសរុបដូចខាងក្រោម:

-ឈ្មោះ [redacted] ប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ចំនួន៣០.០០០.០០០រៀល (សាមសិបលានរៀល)។

-ឈ្មោះ [redacted] ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ចំនួន៣០.០០០.០០០រៀល (សាមសិបលានរៀល)។

ដើមបណ្តឹងរដ្ឋប្បវេណីទាមទារលើសពីនេះបដិសេធចោល។

តាមមាត្រា៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) នៅពន្ធនាគារ ម១ ព្រៃស នៃក្រសួងមហាផ្ទៃ។

តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-សាលក្រមនេះជំនុំជំរះជាសាធារណៈនាថ្ងៃទី២៦, ២៧ ខែធ្នូ ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មេធាវីជនជាប់ចោទទាំងពីរនាក់, ដើមបណ្តឹងនិងជាជនរងគ្រោះឈ្មោះ [redacted] មេធាវីការពារដើមបណ្តឹង និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] អោយប្រកាសជាសាធារណៈនាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២។

ទុកសិទ្ធិប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១០៧ "ឃ" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា:

១-ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣ របស់លោកមេធាវី [redacted] និងសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ របស់លោកមេធាវី [redacted] និងលោក [redacted] ការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ក ជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។



Scanned by CamScanner

២-ពិចារណា និងថ្លឹងថ្លែងឡើងវិញលើសាលក្រមព្រហ្មទណ្ឌលេខ១០៧ "ឃ" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤៤ ក្រIV(ត) ចុះថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣ របស់មេធាវីទទួលសិទ្ធិប្តឹងឧទ្ធរណ៍ឱ្យជនជាប់ចោទឈ្មោះ[redacted]ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-កែប្រែបទចោទប្រកាន់លើឈ្មោះ[redacted]ិងឈ្មោះ [redacted]ីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស មកជាបទផ្តើមគំនិតក្នុងអំពើប្រព្រឹត្តហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមមាត្រា ២៨ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១០៧ "ឃ" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែ:

-ចំណុចទី១នៃសេចក្តីសម្រេចត្រង់ "ផ្តន្ទាទោសឈ្មោះ យ៉ោម បុប្ផា ដាក់ពន្ធនាគារ៣ឆ្នាំ" ត្រូវកែប្រែជា "ផ្តន្ទាទោសឈ្មោះ [redacted]ដាក់ពន្ធនាគារ៣ឆ្នាំ ប៉ុន្តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល២ឆ្នាំ ទោសដែលសល់១ឆ្នាំ ត្រូវព្យួរធម្មតាតាមមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ"។

-ចំណុចទី២នៃសេចក្តីសម្រេចត្រង់: "បង្គាប់ឱ្យជនជាប់ចោទទាំង៤រូប រួមគ្នាសងសំណងអន្តរាយ និងជម្ងឺចិត្តដល់ជនរងគ្រោះឈ្មោ[redacted]ម្នាក់ៗចំនួន៣០លានរៀល" ត្រូវកែប្រែជា "បង្គាប់ឱ្យជនជាប់ចោទទាំង៤រូប រួមគ្នាសងសំណងអន្តរាយ និងជម្ងឺចិត្តដល់ជនរងគ្រោះឈ្មោ[redacted]ងម្នាក់ៗចំនួន១០លានរៀល (ដប់លានរៀលគត់)"។

ចំណុចដទៃទៀតនៃសេចក្តីសម្រេចនៅរក្សាទុកជាបានការដដែល។

៤-បន្តឃុំខ្លួនជនជាប់ចោទឈ្មោ[redacted]ាងលើតាមនីតិវិធី និងបន្តចាប់ខ្លួនជនជាប់ចោទឈ្មោ[redacted]ង[redacted]ាមដីកាបង្គាប់ឱ្យចាប់-ឃុំខ្លួនលេខ៦២៨តព្រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ និងលេខ៦២៩តព្រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ចៅក្រមជំនុំជំរះសាលាដំបូងរាជធានីភ្នំពេញ។

សាលដីកានេះជំនុំជំរះចំពោះមុខមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ[redacted]មេធាវីការពារឱ្យជនរងគ្រោះ ប្រកាសជាសាធារណៈថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។



Scanned by CamScanner

-បានឃើញបណ្តឹងសាទុក្ខលេខ១៩៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ របស់លោក [redacted]មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted]ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៩៤ ក្រIV(ត) ចុះថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាការពារ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ របស់លោ[redacted] និងលោក [redacted]មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ឈ្មោះ[redacted] និងឈ្មោ[redacted]ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: យោងតាមឯកសារដែលមាននៅក្នុងសំណុំរឿងនេះ បានបញ្ជាក់ឲ្យឃើញថា ពិតជាមានករណីអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស បានកើតឡើងនៅចំណុចមុខផ្ទះសំណាក់បុប្ផា ស្ថិតក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ អំពើហិង្សានេះបានកើតឡើងដោយសហចារីដែលដែលមានឈ្មោះ[redacted] ដែលប្រដាប់ដោយអាវុធ រួមមានទូលីវីស និងពូថៅ បានដើរសំដៅទៅរកជនរងគ្រោះឈ្មោ[redacted]ដែលកំពុងអង្គុយនៅចំណុចកើតហេតុ។ នៅពេលទៅដល់ជនជាប់ចោទឈ្មោះ[redacted]បានចាប់គៀកជនរងគ្រោះ[redacted]ហើយ បានយកទូលីវីសចាក់ចំក្បាល និងចំខ្នង បណ្តាលឲ្យមានរបួសជាទម្ងន់។ ចំណែកឯជនជាប់ចោទឈ្មោះ [redacted]បានយកពូថៅកាប់ទៅលើជនរងគ្រោះឈ្មោះ[redacted]ចំក្បាលជាច្រើនកន្លែង បណ្តាលឲ្យមានរបួសជាទម្ងន់ផងដែរ។

ជាមួយគ្នានេះផងដែរ ឯកសារក្នុងសំណុំរឿងនេះ ក៏មានភស្តុតាងដាក់បន្ទុកមួយចំនួន ដែលបានបញ្ជាក់ អំពីការចូលរួមក្នុងការប្រព្រឹត្តបទល្មើសនេះ ដោយជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ [redacted] ផងដែរ ជាពិសេសទាក់ទងនឹងអង្គហេតុដំបូង ដែលបណ្តាលឲ្យមានអំពើហិង្សានេះកើតឡើង គឺដោយសាររឿងរ៉ាវបាត់កញ្ចក់រថយន្តរបស់ជនជាប់ចោទទាំងពីរនាក់នេះ ដែលឲ្យជនជាប់ចោទទាំងពីរមានការសង្ស័យទៅលើជនរងគ្រោះ និងឈានទៅដល់ការបង្គាប់បញ្ជាឲ្យសហចារីដែលប្រើហិង្សាទៅលើជនរងគ្រោះទាំងពីរនាក់បណ្តាលឲ្យមានរបួសយ៉ាងធ្ងន់ធ្ងរ ព្រមទាំងការជួយរំដោះសហចារីដែលផងដែរ។ ទន្ទឹមនេះ ក៏មានចម្លើយសាក្សី និងចម្លើយដោះសាររបស់ជនជាប់ចោទទាំងពីរ ដែលបញ្ជាក់អំពីការមិនបានចូលរួមប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ។ ប៉ុន្តែបើយើងពិនិត្យទៅលើចម្លើយដោះសាររបស់ជនជាប់ចោទ រួមទាំងឯកសារនៅក្នុងសារណាការពារផងដែរថា ចម្លើយដោះសារនេះមានការប្រែប្រួលជាបន្តបន្ទាប់។

ដូច្នេះ សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យពិចារណានូវភស្តុតាងទាំងឡាយដែលមាននៅក្នុងសំណុំរឿងនេះ និងធ្វើការសម្រេចទៅតាមច្បាប់។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted]នាពេលសវនាការថា: តើមូលហេតុអ្វីបានជាអ្នកឯងប្តឹងសាទុក្ខ? ខ្លួនប្តឹងសាទុក្ខមកនេះដោយសារតែខ្លួនមិនបានប្រព្រឹត្ត និងមិនបានបញ្ជាឱ្យបងប្អូនខ្លួនបង្កអំពើហឹង្សា កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ នោះទេ។ ខ្លួនគ្រាន់តែឮសំឡេងឈ្លូសគ្នា ខ្លួនក៏ដើរទៅកន្លែងកើតហេតុ ដោយឃើញមនុស្សច្រើនពេកខ្លួនក៏ត្រឡប់មកវិញ នៅឈរជាមួយ[redacted]ខ្លួនមិនដឹងអ្នកណាឈ្លូសជាមួយអ្នកណាទេ រឿងនេះមានការឃុបឃិតគ្នាជាមួយអាជ្ញាធរថ្នាក់ក្រោម ព្រោះថាខ្លួនជាសកម្មជនតវ៉ាដីធ្លីនៅបឹងកក់។ ខ្លួននៅឈរពីកន្លែងកើតហេតុប្រហែលពី១០ម ទៅ២០ម គឺឈរជជែកគ្នាជាមួយ[redacted]ហើយតុលាការក៏បានសួរចម្លើយសាក្សីរូបនេះហើយដែរ ដែលថាផ្ទះរបស់គាត់នៅជិតកន្លែងកើតហេតុ ចំពោះសាក្សីផ្សេងទៀតខ្លួនមិនច្បាស់ទេ។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្[redacted]នាពេលសវនាការថា: តើអ្នកឯងប្តឹងសាទុក្ខលើចំណុចណាខ្លះ? ខ្លួនប្តឹងសាទុក្ខដោយសារតែខ្លួនមិនបានចូលរួមធ្វើសកម្មភាពហឹង្សាទៅលើជនរងគ្រោះ ដូចបទចោទប្រកាន់របស់តុលាការទេ។ នៅថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូទៅទិញម្ហូប ក៏ឈ្មោ[redacted]ានសួរខ្លួន ខ្លួនក៏ឈប់និយាយជាមួយគ្នាមានទាំងប្រពន្ធរបស់ខ្លួនផងដែរ។ ខ្លួន និងជនរងគ្រោះមិនដែលស្គាល់គ្នាទេពីមុនមក ពេលកើតហេតុខ្លួនមិននៅកន្លែងកើតហេតុផ្ទាល់ទេ គឺនៅចំងាយពីកន្លែងកើហេតុជាង១០ម។ រឿងបាត់កញ្ចក់ឡាន១អាទិត្យ៣ដង នោះខ្លួនបានទៅប្តឹងប៉ូលិស មានឈ្មោះ [redacted] បានទៅជាមួយផងដែរ ដល់ពេលមានរឿងកើតឡើង ក៏យករឿងដែលខ្លួនប្តឹងឱ្យរកចោរនោះ មកភ្ជាប់ជាមួយនឹងរឿងហឹង្សានេះតែម្តង។ ចំពោះឈ្មោ[redacted]នដែលមករស់នៅតំបន់បឹងកក់នេះទេ មូលហេតុអ្វីបានជាមានរឿងហឹង្សានេះកើតឡើង ហើយមកទំលាក់កំហុសមកលើខ្លួន និងប្រពន្ធខ្លួន។

សំណូមពរ: សូមក្រុមប្រឹក្សាជំនុំជម្រះតុលាកាកំពូលជួយរកយុត្តិធម៌ឱ្យខ្លួន និងប្រពន្ធខ្លួនផង ព្រោះពួកខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted]នាពេលសវនាការថា: នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង៧,១០នាទីព្រឹក ខ្លួនបានបករត់ម៉ូតូបកឈប់នៅកន្លែងកើតហេតុជាមួយឈ្មោះ [redacted]ចាំឌុបម៉ូយនោះ ខ្លួនបានឃើញ ឈ្[redacted] ដើរ ហើយឃើញឈ្មោ[redacted] បានលើកដៃចង្អុលមកលើខ្លួន ពេលនោះឈ្មោះ [redacted] បានយកឡូលីវីសមកចាក់លើក្បាលខ្លួន និងខ្នងជាច្រើនកន្លែង រួចខ្លួនក៏រត់ចូលបន្ទប់ផ្ទះរំលោភ

ហើយឈ្មោះនេះក៏មកធាក់ទ្វារចាប់ខ្លួនយកឡូលីវីសមកចាក់ខ្លួនបន្តទៀត ទើបមានអ្នកជិតខាងមកជួយចា[redacted]ានមកជួយរំដោះប្អូនឲ្យរត់គេចខ្លួនរហូតដល់សព្វថ្ងៃនេះ។ ពីមុនមកខ្លួនធ្លាប់ស្គាល់ឈ្មោះ[redacted]និង[redacted]ដោយមានក្មេងៗប្រាប់ខ្លួន។

សំណូមពរ: សុំឲ្យតុលាការកំពូល សម្រេចឲ្យជនជាប់ចោទសងសំណងជាប្រាក់មកឲ្យខ្លួនដើម្បីព្យាបាលជម្ងឺបន្តទៀត។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោ[redacted]ពេលសវនាការថា: នៅថ្ងៃកើតហេតុឈ្មោះ [redacted] បានដើរមកកន្លែងកើតហេតុ ហើយបានលើកដៃចង្អុលខ្លួន រួចក៏មានមនុស្សប្រុស២នាក់មក ដែលឈ្មោះ[redacted]ានយកពូថៅមកកាប់ខ្លួនពីរពូថៅ ដោយចោទខ្លួនថាជាអ្នកលួចកញ្ចក់ឡានគេ។ ឈ្មោះ [redacted]ពេលលើកដៃនោះមិនបាននិយាយអ្វីទេ។ បច្ចុប្បន្ននេះ ខ្លួនមិនទាន់ជាមុខរបួសទេ គឺឈឺចាប់មុខរបួសខ្លាំងនៅពេលត្រជាក់។

សំណូមពរ: សុំឲ្យតុលាការសម្រេចឲ្យជនជាប់ចោទសងសំណងរដ្ឋប្បវេណី យកប្រាក់មកព្យាបាលជម្ងឺបន្តទៀត។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក[redacted]មធាវីការពារឲ្យជនជាប់ចោទ នាពេលសវនាការថា: នីតិវិធីថាមានភស្តុតាង និងសាក្សី តើត្រឹមត្រូវដែរ ឬទេ។ ក្នុងរឿងនេះមិនទាន់ធ្វើបានត្រឹមត្រូវទេ។ ចំពោះមន្ត្រីនគរបាលយុត្តិធម៌ គាត់មិនទាន់បានចុះធ្វើការស្រាវជ្រាវរកវត្ថុតាង ដូចជាពូថៅ, ឡូលីវីស មិនបានធ្វើកំណត់ហេតុនៅកន្លែងកើតហេតុទេ មាត្រា៩០ កំណត់ហេតុនៃការស្រាវជ្រាវ គឺដើម្បីរកស្លាកស្នាម។ ក្នុងរឿងនេះមិនឃើញមានកំណត់ហេតុនៅកន្លែងកើតហេតុទេ អត្តសញ្ញាណជនប្រព្រឹត្តក៏រត់ឃើញដែរ។ ទាក់ទិននឹងការកោះហៅសាក្សី សមត្ថកិច្ចមិនបានកោះហៅទេ មានតែចម្លើយជនរងគ្រោះថា ឮគេថាតែប៉ុណ្ណោះ ដូចនេះជាវិមតិសង្ស័យតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក[redacted]ធាវីការពារឲ្យជនជាប់ចោទ នាពេលសវនាការថា: មានវិមតិសង្ស័យយ៉ាងខ្លាំងចំពោះជនជាប់ចោទ។ កូនក្តីខ្លួនបានឆ្លើយថា មិនដែលបានស្គាល់ជនរងគ្រោះទេ។ អង្គហេតុបាត់កញ្ចក់ឡាន បើកូនក្តីខ្លួនដឹងថាជនរងគ្រោះជាអ្នកលួចកញ្ចក់ឡាននោះ កូនក្តីខ្លួនបានទៅប្តឹងប៉ូលីសឲ្យទៅចាប់បាត់ទៅហើយ មិនចាំបាច់ទៅបញ្ជាឲ្យប្អូនទៅវាយជនរងគ្រោះនោះទេ។ ចំពោះភិនភាគជនជាប់ចោទវិញជនរងគ្រោះស្គាល់មិនច្បាស់ទេ នៅចំពោះមុខសាលាឧទ្ធរណ៍នោះ ហើយនៅចំពោះមុខតុលាការកំពូលឈ្មោះ[redacted] អ្នកកាប់ខ្លួន២ពូថៅ ហើយជនរងគ្រោះ និងសាក្សីថា[redacted]ជាអ្នកបញ្ជា តែជនជាប់ចោទ



Scanned by CamScanner

122/4

មិនស្គាល់ជនរងគ្រោះទេ។ ចំពោះឈ្មោះ [redacted]វិញ តុលាការមិនទាន់ចាប់ខ្លួនបានទេ។ អំពីអត្តសញ្ញាណជនល្មើសជនរងគ្រោះមិនច្បាស់ទេ។ ហេតុការបាត់កញ្ចក់ឡាន មិនមែនជាមូលហេតុដែលបណ្តាលឲ្យមានអំពើហិង្សាទេ។ ចំពោះសាក្សីឈ្មោះ[redacted]ស់ផ្ទះសំណាក់[redacted]ចៅក្រមមិនបានកោះហៅមកសាកសួរយកចម្លើយទេ។ ចំពោះថា កូនក្តីខ្លួនបញ្ជានោះមិនត្រឹមត្រូវទេ ព្រោះថា កូនក្តីខ្លួនឈរនិយាយជាមួយឈ្មោះ [redacted]ងាយពីកន្លែងកើតហេតុជាង១០ម។ ដូចនេះ យោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវតែបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក[redacted] មេធាវីការពារឲ្យជនជាប់ចោទ នាពេលសវនាការថា: ក្នុងរឿងក្តីនេះការមិនសុខចិត្តរបស់កូនក្តីខ្លួនមានពីរចំណុច:

-ចំណុចនៃការផ្តន្ទាទោស ការសម្រេចរបស់សាលាដំបូង យល់ឃើញថា ចារីប្រព្រឹត្តដល់សាលាឧទ្ធរណ៍វិញ ប្តូរបទចោទមកសមគំនិត ដោយរកមិនឃើញពីចារីប្រព្រឹត្ត។ តាមមាត្រា២៨ ផ្តើមគំនិតទៅលើអ្វី បើគម្រោង និងចេតនាក្នុងរឿងនេះគ្មានទេ។ គ្មានចេតនាទៅវាយជនរងគ្រោះទេ គឺដើរទៅហាត់ប្រាណ ដើមចមក្នុងអំពើហិង្សានេះមកពីរឿងបាត់កញ្ចក់ឡាន នោះមិនត្រឹមត្រូវទេ ព្រោះថាកូនក្តីខ្លួនបាត់៣ដង ទើបទៅប្តឹងប៉ូលីស នេះហើយបង្ហាញឲ្យឃើញថា មិនមានគំនិតធ្វើឲ្យជនរងគ្រោះរបួសនោះទេ។ អត្តសញ្ញាណនៃជនដែលអត់មានទេ ទាំងប៉ូលីសមិនបានធ្វើកំណត់ហេតុ គឺធ្វើតាមជនរងគ្រោះថា ឮគេថា ឮក្មេងថា គឺមិនបានកំណត់ឲ្យបានច្បាស់លាស់ទេ។ អ្នកផ្តើមគំនិតជំរុញឲ្យមានការប្រព្រឹត្ត និងបញ្ជា ចំណុចនេះនូវមិនទាន់ច្បាស់ទេ។ អំពើកើតហេតុនៅទិសខាងលិច នៃថ្នល់ម្ខាងទៀតដែលមានចំងាយជាង១០ម ការផ្តន្ទាទោសកូនក្តីខ្លួនតាមមាត្រា២៨, ២១៨ មិនត្រឹមត្រូវទេ គឺគ្រាន់តែសង្ស័យពីវត្តមានប្អូន និងការបាត់កញ្ចក់ឡាន ការសង្ស័យទាំងនេះកុំកំណត់ថាមានទោសអី។

-ចំពោះសំណង វិក័យប័ត្រព្យាបាលរបួសអ្នកទាំងពីរមានប្រមាណ១៥$ប៉ុណ្ណោះ ដែលចេញដោយមន្ទីរពេទ្យកាល់ម៉ែត តែសាលាដំបូងសម្រេចឲ្យសងទាំងពីរនាក់៦០លានរៀល មកសាលាឧទ្ធរណ៍ប្រមាណ២០លានរៀល នោះមិនត្រឹមត្រូវទេ ព្រោះកូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ និងសុំដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាពវិញ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក[redacted]មេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះ នាពេលសវនាការថា: កូនក្តីខ្លួនទទួលរងគ្រោះដោយក្រុមជនល្មើសមានឈ្មោះ [redacted]កើតឡើងដោយសារបាត់កញ្ចក់ឡាន។ ឈ្មោះ [redacted]មនុស្សសាហាវ ហើយត្រូវបានឪពុកម្តាយដេញចេញពីផ្ទះ។ ក្នុងចម្លើយរបស់សាក្សីឈ្មោះ [redacted]នៅកន្លែងកើត

122/3

ហេតុ និងជួយរំដោះប្អូនឈ្មោះ [redacted] ឲ្យរត់គេចខ្លួនបាត់។ អវត្តមានជនជាប់ចោទពីរនាក់នេះ ប៉ុន្តែនៅសល់ជនជាប់ចោទឈ្មោះ [redacted] នៅកន្លែងកើតហេតុដដែល ហើយពិតជាបានរួមគំនិតប្រព្រឹត្តបទល្មើសមកលើកូនក្តីខ្លួនប្រាដកមែន។ ចំពោះសំណងតំលៃព្យាបាលជម្ងឺដែលមេធាវីការពារឲ្យជនជាប់ចោទលើកឡើងថា អស់ប្រមាណជាង១០ម៉ឺនរៀលនោះ មិនត្រឹមត្រូវទេ ពីព្រោះថា របួសស្នាមមើលឃើញជាក់ស្តែង មានខ្លះ៧-៨ថ្នេរ រហូតដល់១០ថ្នេរ និងមានភស្តុតាង និងសាក្សីគ្រប់គ្រាន់ពីជនជាប់ចោទ។

សំណូមពរ: សូមក្រុមប្រឹក្សាជំនុំជម្រះ សម្រេចតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: ទោះបីមានសាក្សីដាក់បន្ទុកក៏ដោយ ក៏មានសាក្សីដោះបន្ទុកផងដែរ ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណាលើភស្តុតាងក្នុងសំណុំរឿង ដើម្បីសម្រេចតាមច្បាប់។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

<u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៩៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ របស់លោក [redacted] ធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា៤១៧,៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលភាគីជនជាប់ចោទប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ៤៤ "ក្រIVគ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនោះ ជាការមិនត្រឹមត្រូវទេ ព្រោះថា តាមស្មារតីនៃមាត្រា២៤ នៃក្រមព្រហ្មទណ្ឌ កំណត់ថា បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។ ករណីនេះ តុលាការកំពូលអាចពិចារណាអំពីបណ្តឹងសាទុក្ខរបស់ភាគីជនជាប់ចោទក្នុងផលប្រយោជន៍របស់ជនជាប់ចោទទាំងពីរ។

-យល់ឃើញថា តាមស្មារតីមាត្រា៣៥៧ (ការសរសេរសាលក្រម៖ ផ្នែកសំអាងហេតុ និងផ្នែកសម្រេច) នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថា នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី ហើយតាមមាត្រា៣៩៦ នៃក្រមដដែល



Scanned by CamScanner

122/2

បានចែងថា "លើសពីនេះ វិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍"។ ករណីនេះ បើពិនិត្យមើលអំពីសំអាងហេតុរបស់សាលាឧទ្ធរណ៍ ឃើញថាសាលាឧទ្ធរណ៍មិនបានឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានប្តឹងសុំរបស់អង្គការអយ្យការ ដែលជាភាគីក្តីមួយដែរនោះទេ។ ដូច្នេះ តាមមាត្រា៤១៩ ចំណុចទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ភាពមិនគ្រប់គ្រាន់នៃសំអាងហេតុ ចាត់ទុកថាគ្មានសំអាងហេតុ។

-យល់ឃើញថា ជនជាប់ចោទជាម្ចាស់បណ្តឹងសាទុក្ខឈ្មោះ [redacted]នឃុំខ្លួននៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ ហើយក្នុងនីតិវិធីនៃការពិនិត្យលើបណ្តឹងសាទុក្ខនេះ ឃើញថា បណ្តឹងសាទុក្ខមានមូលហេតុស្របច្បាប់ទៀត ដូច្នេះ តាមស្មារតីមាត្រា២០៣, ៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៩ ចំណុចទី៣ វាក្យខណ្ឌ២ នៃអនុសញ្ញាសិទ្ធិពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលកំណត់ថាការឃុំខ្លួនមនុស្សដើម្បីរង់ចាំការជនុំជម្រះ គឺមិនមែនជាវិធានការទូទៅទេ ហើយលើសពីនេះទៀតតាមមាត្រា១៤ ចំណុចទី២ នៃអនុសញ្ញាដដែល ក៏កំណត់ផងដែរថា ជនជាប់ចោទត្រូវបានសន្មត់ថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់។ ករណីនេះ ដើម្បីការពារសិទ្ធិរបស់ភាគីជនជាប់ចោទដែលកំពុងជាប់ឃុំក្នុងពេលរង់ចាំនីតិវិធីនៃការពិនិត្យឡើងវិញរបស់សាលាឧទ្ធរណ៍នោះ តុលាការកំពូលគប្បីពិចារណាអំពីសិទ្ធិសេរីភាពរបស់ជនជាប់ឃុំ។

-យល់ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោ[redacted]ពីបទ ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដូចការចោទប្រកាន់ និងផ្តន្ទាទោសរបស់តុលាការអង្គសេចក្តីហើយ។

-យល់ឃើញថា នាពេលសវនាការនេះ តំណាងមហាអយ្យការអមតុលាការកំពូល បានសន្និដ្ឋានថា តាមរយៈភស្តុតាងក្នុងសំណុំរឿង ពិតជាមានអំពើហឹង្សាពិតមែន ដូច្នេះ ប្តឹងសុំអោយក្រុមប្រឹក្សា ពិចារណាតាមច្បាប់។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៤៤ "ក្រIVត" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះ ត្រូវខ្លះខុសខ្លះ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ១៩៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ របស់ភាគីជនជាប់ចោទ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៤៤ "ក្រIVត" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុចស្តីពីការផ្តន្ទាទោសលើឈ្មោះ [redacted] ដែលត្រូវបដិសេធចោល។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ១៩៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មី អំពីចំណុចខាងលើនេះ។



Scanned by CamScanner

៥-បង្គាប់ឲ្យដោះលែងជាបណ្ដោះអាសន្នឈ្មោះ [redacted] បើឈ្មោះនេះមិនត្រូវឃុំខ្លួនពីបទល្មើសផ្សេងទេ។

៦-សាលដីការនេះជំនុំជំរះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី 18 ខែ 5 ឆ្នាំ២០១៤

ក្រឡាបញ្ជី

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី 18 ខែ 5 ឆ្នាំ២០១៤

ជ. ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]



Scanned by CamScanner